**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៧៣៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី

## ការកាត់ដីសរុបទំហំ ៤២១៧,៨៩ ហិកតា នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ក្នុងនោះ កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អ៊ឹមឌីអេស និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូន ប្រជាពលរដ្ឋ ១.០៨៧ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥១៣/៤៦៤ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០៩៦៦ ខ.ពស ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ៤.២១៧,៨៩ ហិកតា ក្នុងនោះ ទំហំ ៤.០២១,៣៦ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៥១៣/៤៦៤ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ និងទំហំ ១៩៦,៥៣ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន **អ៊ឹមឌីអេស** និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ៣.១០៥,៥៣ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១.១១២,៣៦ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិសាត់ ដែលស្ថិតក្នុងភូមិ ដូចខាងក្រោម ៖

- កាត់ផ្ទៃដីសរុបទំហំ **៣.៥៨២,៨០ ហិកតា** ក្នុងនោះ (១) ទំហំ **៣.៤៧៩,០៥ ហិកតា** កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស និង (២) ទំហំ **១០៣,៧៥ ហិកតា** កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន **អ៊ឹមឌីអេស** សម្រាប់ធ្វើប្រទានកម្មទំហំ **២៧០៥,៨៦ ហិកតា** ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ **៨៧៦,៩៤ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅភូមិឯកភាព
- កាត់ផ្ទៃដីសរុបទំហំ **៣៧៤,៦៤ ហិកតា** ក្នុងនោះ (១) ទំហំ **៣៦៥,៣៧ ហិកតា** កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស និង (២) ទំហំ **៩,២៧ ហិកតា** កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន **អ៊ឹមឌីអេស** សម្រាប់ធ្វើប្រទានកម្មទំហំ **២០២,៩៣ ហិកតា** ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ **១៧១,៧១ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិកណ្តាល

- កាត់ផ្ទៃដីសរុបទំហំ ២៦០,៤៥ ហិកតា ក្នុងនោះ ១) ទំហំ ១៧៦,៩៤ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស និង (២) ទំហំ ៨៣,៥១ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន **អ៊ុមឌីអេស** សម្រាប់ធ្វើប្រទានកម្មទំហំ ១៩៦,៧៤ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៦៣,៧១ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិសង្គមថ្មី

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) (២) និង(៣) នៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ១.០៨៧ គ្រួសារ ដែលស្ថិតក្នុងភូមិ ឃុំ ដូចខាងក្រោម ៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **៧៦៨ គ្រួសារ នៅភូមិឯកភាព**
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **១៣៦ គ្រួសារ នៅភូមិកណ្តាល**
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **១៨៣ គ្រួសារ នៅភូមិសង្គមថ្មី** ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*